អង្គភាពសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

Section des co-avocats principaux des parties civiles
Civil Party Lead Co-Lawyers' Section

**សេចក្តីប្រកាសព័ត៌មាន**

## មរណៈភាពរបស់លោក វ៉ាន់ ណាត

រាជធានីភ្នំពេញ ទី ០៦ ខែកញ្ញា ឆ្នាំ២០១១៖ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ក៏ដូចជា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា បានទទួលដំណឹងអំពីមរណៈភាពរបស់លោក **វ៉ាន់ ណាត**។ លោកជាជនរងគ្រោះម្នាក់ដែលនៅរស់ ក្នុងចំណោមជនរងគ្រោះដែលនៅរស់ដ៏តិចតួចនៃមន្ទីរសន្តិសុខ **ទួល ស្លែង** (ស ២១) ដែលជាមន្ទីរសន្តិសុខមួយដ៏សំខាន់បំផុតក្រោមរបបខ្មែរក្រហម។

សហមេធាវីនាំមុខ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ក៏ដូចជា ដើមបណ្តឹងរដ្ឋប្បវេណី សូមផ្ញើរការរំលែកទុក្ខយ៉ាងជ្រាលជ្រៅចំពោះ ក្រុមគ្រួសារ និងញាតិសន្តាននៃសព។

រាល់បណ្តាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់បានដឹងលឺ និងទទួលស្គាល់ការពិតដែលថា លោក **វ៉ាន់ ណាត** បានតស៊ូពេញមួយជីវិតរបស់លោក ដើម្បី ស្វែងរកយុត្តិធម៌ ជនរងគ្រោះត្រូវបានស្តាប់លឺ និងការពិតត្រូវបានដឹង។

គាត់បានសំរេចចិត្តធ្វើសក្ខីកម្ម ប្រឆាំងនឹង **ឌុច** ដែលជាអតីតប្រធានមន្ទីសន្តិសុខ ស ២១។ ការតស៊ូររបស់គាត់បានផ្តល់អោយពួកយើងនូវ គំរូមួយនៃភាពសុច្ចរិត និងក្តីសង្ឃឹម។ ជាអកុសល គាត់គ្មានឪកាសក្នុងការទទួលដឹងលឺនូវ សេចក្តីសម្រេច(សាលដីកា)របស់អង្គជំនុំជម្រៈនៃតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសំរេចក្នុងករណី ០០១ ឡើយ។

ការទទួលមរណៈភាពរបស់លោក វ៉ាន ណាត ក្រើនរំលឹកដល់ពួកយើងនូវភាពចាំបាច់ និងបន្ទាន់ ដែលអង្គជំនុំជម្រះក្នុងករណី០០២ ត្រូវចាប់ផ្តើមឲ្យកាន់តែឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីអនុញ្ញាតឲ្យរាល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៃរបបខ្មែរក្រហមបានឃើញថា ជនដែលត្រូវបានប្តឹងថាបានប្រព្រឹត្តបទឧក្រិដ្ឋលើពួកគាត់ ត្រូវបានគេកាត់ទោស និងដើម្បីអនុញ្ញាតឲ្យមានការផ្សះផ្សារឡើងវិញក្នុងសង្គមកម្ពុជា នាអំឡុងពេល ៣០ឆ្នាំខាងមុខទៀត។

លោក វ៉ាន់ ណាត បានបន្សល់នូវមរតក តាមរយៈរូបគំនូរស្តីពីភាពឃោរឃៅដែលកើតឡើងនៅ មន្ទីរសន្តិសុខ ស២១(ទួលស្លែង) ដែលជាផ្នែកមួយនៃប្រវត្តិសាស្រ្តកម្ពុជា ដែលមិនអាចបំភ្លេចបាន។